# កិច្ចព្រមព្រៀងទីក្រុងស្ត្រាស្បួរ
# ស្តីពីចំណាត់ថ្នាក់ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ

២៤ មីនា ១៩៧១

បានធ្វើវិសោធនកម្ម ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៩

ភាគីហត្ថលេខីទាំងឡាយ

ដោយពិចារណាឃើញថាការអនុម័តយកជាសាកលនៃប្រព័ន្ធឯកសណ្ឋានមួយនៃចំណាត់ថ្នាក់ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រតក្កករ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងវិញ្ញាបនបត្រមានអត្ថប្រយោជន៍ គឺដើម្បីបំរើផលប្រយោជន៍ទូទៅ ដែលនឹងបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្មនិងជាវិភាគទានដើម្បីឱ្យមានសុខដុមនីយកម្មនៃច្បាប់ជាតិក្នុងវិស័យនេះ

ដោយទទួលស្គាល់សារៈសំខាន់នៃអនុសញ្ញាអឺរ៉ុបស្តីពីចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្មលើតក្កកម្ម ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥៤ ដែលក្រុមប្រឹក្សាអឺរ៉ុបបានបង្កើតឱ្យមាន ចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្មលើតក្កកម្ម

ដោយគិតគូរដល់ពតម្លៃជាសាកលនៃចំណាត់ថ្នាក់នេះនិងសារៈសំខាន់នៃចំណាត់ថ្នាក់នេះចំពោះប្រទេសទាំងឡាយជាសមាជិកអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម

ដោយគិតគូរដល់សារៈសំខាន់នៃចំណាត់ថ្នាក់នេះចំពោះប្រទេសកំពុងអភិវឌ្ឍ ដែលបង្កភាពងាយស្រួលក្នុងការទទួលបានបច្ចេកវិទ្យាទំនើបៗដែលចេះតែកើនឡើងឥតឈប់ឈរ

ដោយពិចារណាលើមាត្រា១៩នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ដែលបានកែប្រែនៅទីក្រុង ប្រុយសែល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩០០ នៅទីក្រុង វ៉ាស៊ីនតោន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩១១ នៅទីក្រុងឡាអេ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩២៥ នៅទីក្រុង ឡុង ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ ១៩៣៤ នៅទីក្រុង លីស្បោន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៨ និងនៅទីក្រុង ស្តុកហូម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧

ព្រមព្រៀងដូចតទៅ:

## មាត្រា១

## ការបង្កើតសហភាពពិសេស ការអនុម័តចំណាត់ថ្នាក់អន្តរជាតិ

ប្រទេសដែលកិច្ចព្រមព្រៀងនេះអនុវត្ត ត្រូវបង្កើតសហភាពពិសេសមួយ និងអនុ

ម៉ែតចំណាត់ថ្នាក់រួមនៃប្រកាសនីយបត្រតក្កកម្មលើតក្កកម្ម វិញ្ញាបនបត្រតក្កករ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងវិញ្ញាបនបត្រមានអត្ថប្រយោជន៍ ដែលចាត់ជាចំណាត់ថ្នាក់ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ( តទៅហៅថា ចំណាត់ថ្នាក់)។

## មាត្រា២

## និយមន័យនៃចំណាត់ថ្នាក់

(១)

(ក) ចំណាត់ថ្នាក់រួមមាន:

(i) អត្ថបទដែលបង្កើតឡើង តាមបទប្បញ្ញត្តិនៃអនុសញ្ញាអឺរ៉ុបស្ដីពីចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្មលើតក្កកម្ម ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥៤( តទៅហៅថា អនុសញ្ញាអឺរ៉ុប) ហើយដែលបាន ចូលជាធរមាននិងបោះពុម្ពផ្សាយដោយអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៦៨

(ii)វិសោធនកម្មទាំងឡាយដែលបានចូលជាធរមានតាមមាត្រា២(២)នៃអនុសញ្ញាអឺរ៉ុប មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

(iii) វិសោធនកម្មទាំងឡាយដែលធ្វើឡើងបន្ទាប់តាមមាត្រា៥ ដែលចូលជាធរមានតាមបទប្បញ្ញាត្តិនៃមាត្រា៦។

(ខ) ការណែនាំ និងកំណត់ពន្យល់ទាំងឡាយដែលបញ្ចូលក្នុងអត្ថបទនៃចំណាត់ថ្នាក់ក៏ត្រូវចាត់ទុកជាផ្នែកនៃចំណាត់ថ្នាក់ផងដែរ។

(២)

(ក) អត្ថបទដែលយោងតាមកថាខណ្ឌទី(១)(ក)(i) ត្រូវមានច្បាប់ចម្លងយថាភាព២(ពីរ) ដែលច្បាប់ចម្លងយថាភាពនីមួយៗជាភាសាអង់គ្លេសនិងជាភាសាបារាំង។នៅពេលដែលកិច្ចព្រមព្រៀងនេះបើកចំហសម្រាប់ចុះហត្ថលេខា អត្ថបទមួយត្រូវតម្កល់ជូនអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប និងមួយទៀតត្រូវតម្កល់ជូនអគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក(តទៅហៅរៀងគ្នាថា អគ្គនាយក និង អង្គការ)ដែលបង្កើតឡើងដោយអនុសញ្ញា ១៤ កក្កដា ១៩៦៧ ។

(ខ) វិសោធនដែលយោងតាម កថាខណ្ឌទី(១)(ក)(ii) ត្រូវតម្កល់ច្បាប់ចម្លងយថាភាព២(ពីរ)ដែលច្បាប់ចម្លងនីមួយៗជាភាសាអង់គ្លេសនិងជាភាសាបារាំង។ ច្បាប់ចម្លងមួយត្រូវតម្កល់ជូនអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប ហើយច្បាប់ចម្លងមួយទៀតត្រូវតម្កល់ជូនអគ្គនាយក។

(គ) វិសោធនកម្មដែលយោងតាម កថាខណ្ឌទី(១)(ក)(iii)ត្រូវតម្កល់ច្បាប់ចម្លងយថាភាពតែមួយជាភាសាអង់គ្លេសនិងភាសាបារាំងជូនអគ្គនាយក។

## មាត្រា៣

## ភាសានៃចំណាត់ថ្នាក់

(១) ចំណាត់ថ្នាក់ត្រូវធ្វើឡើងជាភាសាអង់គ្លេសនិងភាសាបារាំង ហើយ អត្ថបទទាំងពីរនេះមានយថាភាពដូចគ្នា។

(២) អត្ថបទផ្លូវការនៃចំណាត់ថ្នាក់ជា ភាសាអាឡឺម៉ង់ ភាសាជប៉ុន ភាសាព័រទុយហ្គាល់ ភាសារុស្ស៊ី ភាសាអេស្ប៉ាញ និងភាសាផ្សេងទៀត ដែលសន្និបាតអាចកំណត់ដូចមានចែងក្នុងមាត្រា៧ ត្រូវធ្វើឡើងដោយការិយាល័យអន្តរជាតិនៃអង្គការ(តទៅហៅថា ការិយាល័យអន្តរជាតិ) ដោយប្រឹក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ និងលើមូលដ្ឋាននៃការបកប្រែបញ្ជូនដោយរដ្ឋាភិបាលទាំងនោះ ឬ ដោយមធ្យោបាយផ្សេងៗទៀត ដែលមិនប៉ះពាល់ដល់បញ្ហាហិរញ្ញវត្ថុនៃថវិការបស់សហភាពពិសេស ឬរបស់អង្គការ។

## មាត្រា៤

## ការប្រើប្រាស់ចំណាត់ថ្នាក់

(១) ចំណាត់ថ្នាក់នេះមានចារិកលក្ខណៈរដ្ឋបាលតែប៉ុណ្ណោះ។

(២) ប្រទេសនីមួយៗនៃសហភាពពិសេសត្រូវមានសិទ្ធិប្រើប្រាស់ចំណាត់ថ្នាក់ជាប្រព័ន្ធគោលឬប្រព័ន្ធបន្ទាប់បន្សំ។

(៣) អាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសនៃសហភាពពិសេសត្រូវបញ្ចូលៈ

- (i) ក្នុងប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រតក្កករ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងវិញ្ញាបនបត្រមានអត្ថប្រយោជន៍ដែលចេញដោយអាជ្ញាធរទាំងនេះនិងសំណុំលិខិតស្នើសុំទាំងឡាយដែលពាក់ព័ន្ធទោះបីបើត្រូវបានបោះពុម្ពផ្សាយឬគ្រាន់តែដាក់ឱ្យសាធារណៈជនអង្កេតដោយអាជ្ញាធរទាំងនេះក៏ដោយ ហើយ
- (ii) ក្នុងកំណត់ពន្យល់ដែលមានក្នុងព្រឹត្តិប័ត្រផ្លូវការដែលបានបោះពុម្ពផ្សាយឬការដាក់ជាសាធារណៈនូវឯកសារដូចមានចែងក្នុងអនុកថាខណ្ឌ(i)

នូវនិមិត្តសញ្ញាពេញលេញនៃចំណាត់ថ្នាក់ដែលអនុវត្តចំពោះតក្កកម្មដែលជាកម្មវត្ថុនៃឯកសារ ដូចមានចែងក្នុងអនុកថាខណ្ឌ(i) ។

(៤) នៅពេលចុះហត្ថលេខាកិច្ចព្រមព្រៀងនេះ ឬនៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកៈ

(i) ប្រទេសណាមួយអាចប្រកាសថាខ្លួនមិនសន្យាបញ្ចូលនិមិត្តសញ្ញាពាក់ព័ន្ធនឹងក្រុមឬអនុក្រុមនៃចំណាត់ថ្នាក់ក្នុងសំណុំលិខិតស្នើសុំដូចមានចែងក្នុងកថាខណ្ឌទី៣ ដែលគ្រាន់តែដាក់ឱ្យសាធារណៈជនអង្កេតនិងក្នុងកំណត់ពន្យល់ដែលពាក់ព័ន្ធនឹងចំណាត់ថ្នាក់ ហើយ

(ii) ប្រទេសណាមួយដែលមិនត្រួតពិនិត្យ ភាពថ្មី ទោះជាភ្លាមៗ ឬមានការពន្យាពេល ហើយដែលនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬប្រភេទផ្សេងទៀតនៃកិច្ចការពារមិនមានចែងអំពីការស្រាវជ្រាវស្នាដៃដែលមាន អាចប្រកាសថាខ្លួនមិនសន្យាបញ្ចូលនិមិត្តសញ្ញាពាក់ព័ន្ធនឹងក្រុមនិងអនុក្រុមនៃចំណាត់ថ្នាក់ក្នុងឯកសារនិងកំណត់ពន្យល់ដូចមានចែងក្នុងកថាខណ្ឌទី៣។ ប្រសិនបើ លក្ខខណ្ឌទាំងនេះមានចំពោះតែប្រភេទនៃកិច្ចការពារមួយចំនួនឬវិស័យមួយចំនួននៃបច្ចេកវិទ្យា ប្រទេសទាំងនេះ អាចធ្វើខដាក់លក្ខខណ្ឌតែត្រឹមដែលលក្ខខណ្ឌទាំងនេះអនុវត្ត។

(៥) និមិត្តសញ្ញានៃចំណាត់ថ្នាក់ ដែលមានសរសេរពាក្យ ចំណាត់ថ្នាក់ប្រកាសនីយបត្រតក្កកម្មអន្តរជាតិឬពាក្យកាត់ដែលកំណត់ដោយគណៈកម្មាធិការជំនាញដូចមានចែងក្នុងមាត្រា៥ ត្រូវបោះពុម្ពជាអក្សរដុតៗឬក្នុងលក្ខណៈដែលអាចមើលឃើញច្បាស់ ក្នុងចំណងជើងឯកសារ នីមួយៗដូចមានចែងក្នុងកថាខណ្ឌទី៣(i)ដែលត្រូវបញ្ចូលនិមិត្តសញ្ញា។

(៦) ប្រសិនបើប្រទេសណាមួយនៃសហភាពពិសេសផ្តល់សិទ្ធិផ្តល់ប្រកាសនីយបត្រតក្កកម្មទៅអាជ្ញាធរអន្តររដ្ឋាភិបាលមួយ ប្រទេសនេះត្រូវចាត់វាល់វិធានការដើម្បីធានាថាអាជ្ញាធរនេះប្រើប្រាស់ចំណាត់ថ្នាក់ឱ្យស្របតាមមាត្រានេះ។

## មាត្រា៥
## គណៈកម្មាធិការជំនាញ

(១) គណៈកម្មាធិការជំនាញត្រូវបង្កើតឡើងដោយមានតំណាងពីប្រទេសនីមួយៗនៃសហភាពពិសេស។

(២)

(ក) អគ្គនាយកត្រូវអញ្ជើញអង្គការអន្តររដ្ឋាភិបាលដែលជំនាញក្នុងវិស័យប្រកាសនីយបត្រតក្កកម្មហើយយ៉ាងហោចណាស់ប្រទេសជាសមាជិកមួយនៃសមាជិកទាំងឡាយជាភាគីនៃកិច្ចព្រមព្រៀងនេះ ត្រូវតំណាងដោយអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំគណៈកម្មាធិការជំនាញ។

(ខ) អគ្គនាយកអាចអញ្ជើញហើយប្រសិនបើមានសំណើពីគណៈកម្មាធិការជំនាញ

ត្រូវអញ្ជើញតំណាងនៃអង្គការអន្តរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិផ្សេងៗ ទៀតឱ្យចូលរួមក្នុងកិច្ចពិភាក្សាពីផលប្រយោជន៍ដែលទាក់ទងនឹងអង្គការទាំងនេះ។

(៣) គណៈកម្មាធិការជំនាញត្រូវៈ

(i) ធ្វើវិសោធនកម្មចំណាត់ថ្នាក់

(ii) ផ្តល់អនុសាសន៍ដល់ប្រទេសនៃសហភាពពិសេសក្នុងគោលបំណងជួយសម្រួលដល់ការប្រើប្រាស់ចំណាត់ថ្នាក់និងជំរុញឱ្យមានឯកសណ្ឋានភាពចំពោះការអនុវត្តន៍

(iii) ជួយជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការចាត់ថ្នាក់ឡើងវិញនៃសំណុំឯកសារដែលប្រើប្រាស់សម្រាប់ត្រួតពិនិត្យតក្កកម្ម ដោយពិចារណាពីតម្រូវការនៃប្រទេសកំពុងអភិវឌ្ឍ

(iv) ចាត់រាល់វិធានការផ្សេងៗទៀតដែលអាចផ្តល់វិភាគទានដល់ការជួយសម្រួលការអនុវត្តន៍ចំណាត់ថ្នាក់ដោយប្រទេសកំពុងអភិវឌ្ឍ ដែលមិនប៉ះពាល់ដល់បញ្ហាហិរញ្ញវត្ថុនៃថវិការបស់សហភាពពិសេស ឬ របស់អង្គការ

(v) មានសិទ្ធិបង្កើតអនុគណៈកម្មាធិការនិងក្រុមការងារ។

(៤) គណៈកម្មាធិការជំនាញត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ បទបញ្ជាទាំងនេះត្រូវផ្តល់លទ្ធភាពឱ្យមានការចូលរួមពីអង្គការអន្តរដ្ឋាភិបាល ដូចមានចែងក្នុងកថាខណ្ឌទី២(ក)ក្នុងកិច្ចប្រជុំអនុគណៈកម្មាធិការនិងក្រុមការងារ ដែលអាចបំពេញការងារជាសារវន្តក្នុងការអភិវឌ្ឍន៍ចំណាត់ថ្នាក់។

(៥) សំណើធ្វើវិសោធកម្មចំណាត់ថ្នាក់ អាចធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសណាមួយនៃសហភាពពិសេស ដោយការិយាល័យអន្តរជាតិ ដោយអង្គការអន្តរដ្ឋាភិបាលណាមួយដែលមានតំណាងក្នុងគណៈកម្មាធិការជំនាញតាមកថាខណ្ឌទី២(ក) និងដោយអង្គការផ្សេងៗទៀត ដែលអញ្ជើញជាពិសេសដោយគណៈកម្មាធិការជំនាញឱ្យដាក់សំណើនេះ។ រាល់សំណើត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ ដែលត្រូវបញ្ជូនសំណើទាំង នេះទៅសមាជិកនៃគណៈកម្មាធិការជំនាញនិងទៅអ្នកសង្កេតការណ៍ មិនឱ្យលើសពី២(ពីរ)ខែ មុនសម័យប្រជុំគណៈកម្មាធិការជំនាញលើកយកសំណើមកពិចារណា។

(៦)

(ក) ប្រទេសជាសមាជិកនីមួយៗនៃគណៈកម្មាធិការជំនាញត្រូវមានសំលេងឆ្នោតតែមួយ។

(ខ) សេចក្តីសម្រេចនៃគណៈកម្មាធិការជំនាញ ទាមទារសំលេងឆ្នោតភាគច្រើនធម្មតានៃប្រទេសដែលមានតំណាងនិងដែលបានបោះឆ្នោត។

(គ) សេចក្តីសម្រេចនៃ១/៥(មួយភាគប្រាំ)នៃប្រទេសដែលមានតំណាងនិងបានបោះឆ្នោតយល់ឃើញថាប៉ះពាល់ដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធជាមូលដ្ឋាននៃចំណាត់ថ្នាក់ ឬដែលប៉ះពាល់ដល់ការងារជាសារវន្តនៃការចាត់ថ្នាក់ឡើងវិញទាមទារសំលេងភាគច្រើន ៣/៤(បីភាគបួន)នៃប្រទេសដែលមានតំណាងនិងបានបោះឆ្នោត។

(ឃ) អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

## មាត្រា៦

## ការជូនដំណឹង ការចូលជាធរមាន ការបោះពុម្ពផ្សាយនៃវិសោធនកម្ម និងសេចក្តីសម្រេចផ្សេងទៀង

(១) រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជំនាញពាក់ព័ន្ធនឹងការអនុម័តវិសោធនកម្មចំណាត់ថ្នាក់និងអនុសាសន៍គណៈកម្មាធិការជំនាញ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយនៃប្រទេសក្នុងសហភាពពិសេស។ វិសោធនកម្មត្រូវចូលជាធរមាន៦(ប្រាំមួយ)ខែរាប់ចាប់ពីការបញ្ជូនសេចក្តីជូនដំណឹងនេះ។

(២) ការិយាល័យអន្តរជាតិត្រូវបញ្ចូលក្នុងចំណាត់ថ្នាក់នូវវិសោធនកម្មទាំងឡាយដែលបានចូលជាធរមាន។ សេចក្តីប្រកាសនៃវិសោធនកម្មត្រូវបោះផ្សាយក្នុងព្រឹត្តិប័ត្រ ដូចបានកំណត់ដោយសន្និបាតដូចមានចែងក្នុងមាត្រា៧។

## មាត្រា៧

## សន្និបាតនៃសហភាពពិសេស

(១)

(ក) សហភាពពិសេសត្រូវមានសន្និបាតមួយ ដែលរួមមានប្រទេសទាំងអស់នៃសហភាពពិសេស។

(ខ) រដ្ឋាភិបាលនៃប្រទេសនីមួយៗដូចមានចែងក្នុងមាត្រា៥(២)(ក) ត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាចអមដោយ ប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

(គ) អង្គការអន្តររដ្ឋាភិបាលណាមួយ ដូចមានចែងក្នុងមាត្រា៥(២)(ក) អាចតំណាងដោយអ្នកសង្កេតការណ៍មួយរូបក្នុងកិច្ចប្រជុំទាំងឡាយនៃសន្និបាត ហើយប្រសិនបើសន្និបាតសម្រេចបែបនេះ អាចតំណាងដោយអ្នកសង្កេតការណ៍មួយរូបក្នុងកិច្ចប្រជុំ គណៈកម្មាធិការ ឬក្រុមការងារដែលបានបង្កើតឡើងដោយសន្និបាត។

(ឃ) រាល់ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនោះ។

(២)

(ក) លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៥ សន្និបាតត្រូវៈ

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍សហភាពពិសេស និងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ

(ii) ណែនាំការិយាល័យអន្តរជាតិអំពីការរៀបចំសន្និសីទកែប្រែ

(iii) ត្រួតពិនិត្យនិងអនុម័តរបាយការណ៍និងសកម្មភាពអគ្គនាយកដែលពាក់ព័ន្ធនឹងសហភាពពិសេស ហើយផ្តល់ការណែនាំតាមការចាំបាច់ដល់អគ្គនាយកពាក់ព័ន្ធនឹងបញ្ហាក្នុងសមត្ថកិច្ចរបស់សហភាពពិសេស

(iv) កំណត់កម្មវិធី និងអនុម័តថវិកាពីរឆ្នាំម្តងនៃសហភាពពិសេស និងអនុម័តការបិទបញ្ជីគណនី

(v) អនុម័តបទបញ្ញាស្តីពីហិរញ្ញវត្ថុរបស់សហភាពពិសេស

(vi) សម្រេចបង្កើតអត្ថបទផ្លូវការនៃចំណាត់ថ្នាក់ជាភាសាផ្សេង ក្រៅពីភាសាអង់គ្លេស ភាសាបារាំង និងភាសាដូចមានចែងក្នុងមាត្រា៣(២)

(vii) បង្កើតគណៈកម្មាធិការនិងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស

(viii) លើកលែងតែកថាខណ្ឌទី១(គ) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ចំពោះប្រទេសដែលមិនមែនជាសមាជិកសហភាពពិសេសនិង អង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល និងចំពោះគណៈកម្មាធិការឬក្រុមការងារដែលបង្កើតដោយសហភាព

(ix) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស

(x) បំពេញមុខងារផ្សេងទៀតដែលស្របតាមអនុសញ្ញានេះ។

(ខ) ចំពោះបញ្ហាដែលពាក់ព័ន្ធផងដែរនឹងផលប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៣ )

(ក) ប្រទេសនីមួយៗជាសមាជិកនៃសន្និបាតមានសំលេងឆ្នោតតែមួយ។

(ខ) កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសជាសមាជិកសន្និបាត។

(គ) ក្នុងករណីមិនគ្រប់កូរ៉ុម សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះត្រូវយកមកអនុវត្តបាន តែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាត។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ទៅប្រទេសជាសមាជិកសន្និបាតទាំងឡាយដែលគ្មានវត្តមាន និងត្រូវអញ្ជើញប្រទេសទាំងនេះ ឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេល៣(បី)ខែរាប់ចាប់ពីថ្ងៃជូនដំណឹង។ បើផុតរយៈពេលនេះ ប្រសិនបើចំនួននៃប្រទេសដែលបានបោះឆ្នោតឬបោះឆ្នោតអនុប្បវាទ ស្មើនឹងចំនួនប្រទេសដែលខ្វះសម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្តីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សំលេងភាគច្រើនដែលទាមទារ ។

(ឃ) លើកលែងតែបទប្បញ្ញត្តិនៃមាត្រា១១(២) សេចក្តីសម្រេចរបស់សន្និបាតត្រូវធ្វើឡើងដោយសំលេងភាគច្រើន២/៣(ពីរភាគបី)នៃសំលេងឆ្នោតដែលបានបោះ។

(ង) អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

(ច) ប្រតិភូម្នាក់អាចជាតំណាង និងបោះឆ្នោតក្នុងនាម ឱ្យប្រទេសមួយតែប៉ុណ្ណោះ។

(៤)

(ក) សន្និបាតត្រូវប្រជុំសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ។

(ខ) តាមសំណើសុំពីប្រទេសជាសមាជិកសន្និបាតចំនួន១/៤(មួយភាគបួន) សន្និបាតត្រូវប្រជុំវិសាមញ្ញបាន តាមការកោះប្រជុំរបស់អគ្គនាយក ។

(គ) អគ្គនាយកជាអ្នករៀបចំរបៀបវារៈកិច្ចប្រជុំនីមួយៗ។

(៥) សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា៨

## [ ការិយាល័យអន្តរជាតិ ]

(១)

(ក) ការងាររដ្ឋបាលរបស់សហភាពពិសេសត្រូវបំពេញដោយការិយាល័យអន្តរជាតិ។

(ខ) ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំកិច្ចប្រជុំនិងបំរើការងារជាលេខាធិការដ្ឋាន សម្រាប់សន្និបាត សម្រាប់គណៈកម្មាធិការជំនាញ និងគណៈកម្មាធិការនិងក្រុមការងារផ្សេងទៀត ដែលបង្កើតឡើងដោយសន្និបាត ឬដោយគណៈកម្មាធិការជំនាញ។

(គ) អគ្គនាយកនៃអង្គការត្រូវជានាយកប្រតិបត្តិនៃសហភាពពិសេសនិងជា តំណាងសហភាពពិសេស។

(២) អគ្គនាយក និងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកត្រូវចូលរួមរាល់កិច្ចប្រជុំ សន្និបាត គណៈកម្មាធិការជំនាញ និងគណៈកម្មាធិការនិងក្រុមការងារផ្សេងៗទៀតដែលបង្កើតឡើងដោយសន្និបាត ឬគណៈកម្មាធិការជំនាញ តែគ្មានសិទ្ធិបោះឆ្នោតទេ។ អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនេះ។

(៣)

(ក) តាមសេចក្តីណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែ។

(ខ) ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាលនិងអង្គអន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ។

(គ) អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយកត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទកែប្រែទាំងនេះ តែគ្មានសិទ្ធិបោះឆ្នោតទេ។

(៤) ការិយាល័យអន្តរជាតិត្រូវអនុវត្តការងារផ្សេងៗទៀត។

## មាត្រា៩

## [ហិរញ្ញវត្ថុ]

(១)

(ក) សហភាពពិសេសត្រូវមានថវិការបស់ខ្លួន។

(ខ) ថវិការបស់សហភាពពិសេសរួមមានខ្ទង់ចំនូលនិងខ្ទង់ចំណាយផ្ទាល់របស់សហភាពពិសេស វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព និងបើមានចំនួនទឹកប្រាក់ដែលមានក្នុងថវិការបស់សន្និសីទនៃអង្គការ។

(គ) ការចំណាយដែលមិនមែនជាចំនាយផ្តាច់មុខរបស់សហភាពពិសេស ប៉ុន្តែជាការចំណាយរបស់សហភាពមួយ ឬច្រើនផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព។ ចំណែកនៃសហភាពពិសេសក្នុង

ខ្ទង់ចំណាយរួមនេះត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពពិសេសទទួលបាន ក្នុងចំនាយរួមនេះ។

(២) ថវិការបស់សហភាពពិសេសត្រូវបង្កើតឡើយ ដោយផ្អែកលើតម្រូវការសម្របសម្រួល ជាមួយថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ។

(៣) ថវិការបស់សហភាពពិសេសទទួលបានពីប្រភពនានាដូចខាងក្រោម:

(i) វិភាគទានពីប្រទេសនៃសហភាពពិសេស

(ii) កម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិ ក្នុងនាមសហភាពពិសេស

(iii) ការលក់ ឬលាភការ ពីការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិ ពាក់ព័ន្ធនឹងសហភាពពិសេស

(iv) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(v) ការជួល ការប្រាក់ និងចំនូលផ្សេងៗទៀត។

(៤)

(ក) ដើម្បីបង្កើតជាវិភាគទាននៃថវិកាដូចមានចែងក្នុងកថាខណ្ឌ៣(i) ប្រទេសនីមួយៗនៃសហភាពពិសេសត្រូវស្ថិតក្នុងថ្នាក់ដូចគ្នាដូចទៅនឹងចំណាត់ថ្នាក់របស់សហភាពក្នុងអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយត្រូវបង់វិភាគទានប្រចាំឆ្នាំផ្អែកតាមចំនួនដូចគ្នានៃឯកតា ដូចដែលបានកំណត់សម្រាប់ចំណាត់ថ្នាក់ក្នុងសហភាពនោះ។

(ខ) វិភាគទានប្រចាំឆ្នាំនៃប្រទេសនីមួយៗនៃសហភាពពិសេស ត្រូវមានចំនួនសមាមាត្រគ្នានឹងចំនួនសរុបដែលបានធ្វើវិភាគទានទៅថវិការបស់សហភាពពិសេសដោយប្រទេសទាំងអស់ដូចនឹងចំនួនឯកតារបស់ខ្លួនទៅចំនួនសរុបនៃឯកតានៃប្រទេសផ្តល់វិភាគទានទាំងអស់។

(គ) ការបង់វិភាគទានត្រូវធ្វើឡើងនៅថ្ងៃទី ១ ខែ មករា ជារៀងរាល់ឆ្នាំ។

(ឃ) ប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទាន មិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពនៃសហភាពពិសេស ប្រសិនបើចំនួនដែលមិនបានបង់មានចំនួនស្មើ ឬលើសពីចំនួននៃវិភាគទានត្រូវបង់ចំនួនពីរឆ្នាំពេញ។ ប៉ុន្តែអង្គភាពណាមួយនៃសហភាពពិសេស អាចអនុញ្ញាតឱ្យប្រទេសដែលយឺតយ៉ាវអាចបន្តអនុវត្តសិទ្ធិបោះឆ្នោតក្នុងអង្គភាពនោះបាន ដរាបណាបានផ្តល់ហេតុផលត្រឹមពីការយឺតយ៉ាវក្នុងការបង់វិភាគទាន ដោយកាលៈទេសៈពិសេស និងមិនអាចជៀសវាងបាន។

(ង) ប្រសិនបើ ថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានោះត្រូវតែចាត់ទុកថាមានកម្រិតស្មើគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ។

(៥) បរិមាណនៃកម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាពពិសេសនឹងត្រូវកំណត់ ហើយរាយការណ៍ទៅសន្និបាតដោយអគ្គនាយក។

(៦)

(ក) សហភាពពិសេសត្រូវមានមូលនិធិទុនបង្វិលដែលទទួលបានពីការបង់ប្រាក់សរុបរួមតែមួយពីប្រទេសនីមួយៗនៃសហភាពពិសេស។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតអាចសម្រេចបង្កើនមូលនិធិនេះបាន។

(ខ) ចំនួននៃការបង់ប្រាក់ដំបូងរបស់ប្រទេសនីមួយៗក្នុងមូលនិធិនេះ ឬនៃការចូលរួមរបស់ខ្លួនក្នុងការបង្កើនមូលនិធិ ត្រូវសមាមាត្រនឹងវិភាគទាននៃប្រទេសនោះសម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះ ឬឆ្នាំនៃការសម្រេចបង្កើនមូលនិធិ។

(គ) សមាមាត្រ និងលក្ខខណ្ឌនៃការបង់ប្រាក់ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក និងបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

(៧)

(ក) នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការដែលបានចុះជាមួយប្រទេសដែលអង្គការដាក់ទីស្នាក់ការនៅលើទឹកដីប្រទេសនោះ ត្រូវចែងថានៅពេលណាដែលមូលនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនោះត្រូវបង់ប្រាក់ជាមុន។ ចំនួននៃប្រាក់បង់ជាមុននិងលក្ខខណ្ឌនៃការបង់ជាមុន ត្រូវកំណត់ដោយកិច្ចព្រមព្រៀងដោយឡែកពីគ្នារវាងប្រទេសនោះនឹងអង្គការ។

(ខ) ប្រទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក) និងអង្គការ ត្រូវមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះត្រូវមានអានុភាពក្នុងរយៈពេលបី(៣)ឆ្នាំបន្ទាប់ពីបំណាច់ឆ្នាំនៃការជូនដំណឹង។

(៨) សវនកម្មគណនី ត្រូវធ្វើឡើងដោយប្រទេសមួយឬច្រើននៃសហភាពពិសេស ឬដោយសវនករខាងក្រៅ ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ ហើយត្រូវចាត់តាំងដោយសន្និបាតដោយមានការយល់ព្រមពីសវនករនេះ។

## មាត្រា១០

## ការកែប្រែកិច្ចព្រមព្រៀង

(១) កិច្ចព្រមព្រៀងនេះអាចត្រូវបានកែប្រែបានពេលណាក៏បានដោយសន្និសីទពិសេសនៃប្រទេសទាំងឡាយរបស់សហភាពពិសេស។

(២) ការកោះប្រជុំសន្និសីទកែប្រែត្រូវសម្រេចដោយសន្និបាត។

(៣) មាត្រា ៧ មាត្រា ៨ មាត្រា ៩ និងមាត្រា ១១ អាចធ្វើវិសោធនកម្មដោយសន្និសីទកែប្រែ ឬតាមបទប្បញ្ញត្តិនៃមាត្រា ១១ ក៏បាន។

## មាត្រា១១

## វិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃកិច្ចព្រមព្រៀង

(១) សំណើធ្វើវិសោធនកម្មមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រានេះ អាចផ្តើមគំនិតដោយប្រទេសណាមួយនៃសហភាពពិសេស ឬដោយអគ្គនាយក។ អគ្គនាយកត្រូវជូនដំណឹងពីសំណើនេះទៅប្រទេសទាំងឡាយនៃសហភាពពិសេស យ៉ាងហោចណាស់ ៦(ប្រាំមួយ)ខែមុនសន្និបាតលើកយកមកពិចារណា។

(២) វិសោធនកម្មមាត្រាទាំងឡាយដូចមានចែងក្នុងកថាខណ្ឌទី(១) ត្រូវអនុម័តដោយសន្និបាត។ ការអនុម័តត្រូវទាមទារសំលេងឆ្នោត៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ តែចំពោះវិសោធនកម្មមាត្រា៧និងចំពោះកថាខណ្ឌនេះត្រូវទាមទារសំលេង៤/៥(បួនភាគប្រាំ)នៃសំលេងឆ្នោតដែលបានបោះ។

(៣)

(ក) វិសោធនកម្មមាត្រាណាមួយដូចមានចែងក្នុងកថាខណ្ឌទី(១) ត្រូវចូលជាធរមាន ១(មួយ)ខែបន្ទាប់ពីអគ្គនាយកទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងស្របតាមដំណើរការរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ ចំនួន៣/៤(បីភាគបួន)នៃប្រទេសជាសមាជិកសហភាពពិសេសនៅពេលដែលវិសោធនកម្មនោះបានអនុម័ត ។

(ខ) វិសោធនកម្មណាមួយចំពោះមាត្រាទាំងនេះ ដែលបានទទួលយកត្រូវចងភ្ជាប់ប្រទេសទាំងអស់ដែលជាសមាជិកនៃសហភាពពិសេសនៅពេលដែលវិសោធនកម្មទាំងនោះ ចូលជាធរមាន។ ចំពោះវិសោធនកម្មដែលបង្កើនកាតព្វកិច្ចហិរញ្ញវត្ថុរបស់ប្រទេសនៃសហភាព ពិសេសត្រូវចងភ្ជាប់តែប្រទេសដែលបានជូនដំណឹងពីការទទួលយករបស់ពួកគេចំពោះវិសោធនកម្មនោះ។

(គ) វិសោធនកម្មណាមួយដែលទទួលយកតាមបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក) ត្រូវចងភ្ជាប់ប្រទេសទាំងអស់ ដែលក្លាយជាសមាជិកនៃសហភាពពិសេសបន្ទាប់ពីកាលបរិច្ឆេទដែលវិសោធនកម្មចូលជាធរមានស្របតាមបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក)។

## មាត្រា១២
## ការក្លាយជាសមាជិកកិច្ចព្រមព្រៀង

(១) ប្រទេសណាមួយជាភាគីនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម អាចក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះដោយៈ

(i) ចុះហត្ថលេខាបន្ទាប់ពីតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬ

(ii) តម្កល់លិខិតុបករណ៍នៃការចូលជាសមាជិក

(២) លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គនាយក។

(៣) បទប្បញ្ញត្តិមាត្រា២៤ នៃច្បាប់ស្តុកហូម នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ។

(៤) កថាខណ្ឌទី(៣) មិនត្រូវយល់ថាជាការទទួលស្គាល់ឬ ជាការទទួលយកដោយតុណ្ហីភាពដោយប្រទេសមួយនៃសហភាពពិសេសចំពោះស្ថានភាពជាក់ស្តែងពាក់ព័ន្ធនឹងដែនដីដែលកិច្ចព្រមព្រៀងនេះអាចអនុវត្តបានដោយប្រទេសមួយផ្សេងទៀតតាមអត្ថន័យនៃកថាខណ្ឌខាងលើ។

## មាត្រា១៣
## ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

(១)

(ក) កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន១(មួយ)ឆ្នាំបន្ទាប់ពីលិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកបានតម្កល់ដោយៈ

(i) ប្រទេស២/៣(ពីរភាគបី)ដែលជាភាគីអនុសញ្ញាអឺរ៉ុបតាមកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះបានបើកចំហសម្រាប់ចុះហត្ថលេខា និង

(ii) ប្រទេសចំនួន៣(បី) ដែលជាភាគីអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ដែលពីមុនមិនមែនជាភាគីអនុសញ្ញាអឺរ៉ុប ហើយដែលយ៉ាងហោចណាស់ប្រទេសមួយជាប្រទេសដែលបានដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មឬ វិញ្ញាបនបត្រតក្កករច្រើនជាង៤០,០០០ ដោយយកតាមស្ថិតិប្រចាំឆ្នាំថ្មីបំផុតដែលបានបោះផ្សាយដោយការិយាល័យអន្តរជាតិ តាមកាលបរិច្ឆេទតម្កល់លិខិតុ-បករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិករបស់ខ្លួន។

(ខ) ចំពោះប្រទេសណាមួយ ក្រៅពីប្រទេសដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានតាមអនុកថាខណ្ឌ(ក) ត្រូវចូលជាធរមាន ១ (មួយ)ឆ្នាំរាប់ចាប់ពី កាលបរិច្ឆេទដែល ការ

ផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃប្រទេសនេះ ត្រូវបានជូន ដំណឹងដោយអគ្គនាយក ប្រសិនបើគ្មានការចង្អុលបង្ហាញពីកាលបរិច្ឆេទបន្ទាប់ណាមួយនៅក្នុងលិខិតុ-បករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក។ ករណីក្រោយនេះ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានចំពោះប្រទេសនោះនៅកាលបរិច្ឆេទ ដែលបានចង្អុលបង្ហាញ។

(គ) ប្រទេសទាំងឡាយជាភាគីអនុសញ្ញាអឺរ៉ុបដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកអនុសញ្ញានេះ តម្រូវឱ្យប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ យ៉ាងយូរបំផុតចាប់ថ្ងៃ ដែលកិច្ចព្រមព្រៀងនេះចូលជាធរមានចំពោះប្រទេសទាំងនេះ។

(២) ការផ្តល់សច្ចាប័នឬការចូលជាសមាជិក តម្រូវជាស្វ័យប្រវត្តិឱ្យយល់ព្រមទទួលយករាល់ខ និងអត្ថប្រយោជន៍ទាំងអស់នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៤

## រយៈពេលនៃកិច្ចព្រមព្រៀងនេះ

កិច្ចព្រមព្រៀងនេះត្រូវមានរយៈពេលការពារ ដូចទៅនឹងអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។

## មាត្រា១៥

## ការប្រកាសដកខ្លួនចេញ

(១) ប្រទេសណាមួយនៃសហភាពពិសេសអាចប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ដោយជូនដំណឹងទៅអគ្គនាយក។

(២) ការប្រកាសដកខ្លួនចេញត្រូវមានអានុភាព១(មួយ)ឆ្នាំរាប់ចាប់ពីថ្ងៃ ដែលអគ្គនាយកទទួលបានការជូនដំណឹង។

(៣) សិទ្ធិប្រកាសដកខ្លួនចេញដែលបានចែងក្នុងមាត្រានេះ មិនត្រូវអនុវត្តដោយប្រទេសណាមួយមុនផុតកំណត់រយៈពេល៥(ប្រាំ)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទដែលប្រទេសនោះក្លាយជាសមាជិកសហភាពពិសេសនេះ។

## មាត្រា១៦

## ការចុះហត្ថលេខា ភាសា ការជូនដំណឹង មុខងារតម្កល់

(១)

(ក) កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខានៅក្នុងអត្ថបទដើមមួយ ជាភាសាអង់គ្លេស និងភាសបារាំង។ អត្ថបទទាំងពីរមានយថាភាពដូចគ្នា។

(ខ) កិច្ចព្រមព្រៀងនេះ នៅតែបើកចំហសម្រាប់ចុះហត្ថលេខានៅទីក្រុងស្ត្រាស្បួរ រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧១។

(គ) អត្ថបទដើមនៃកិច្ចព្រមព្រៀងនេះ នៅពេលបញ្ឈប់ការបើកចំហសម្រាប់ការចុះហត្ថលេខា ត្រូវតម្កល់ជូនអគ្គនាយក។

(២) អត្ថបទផ្លូវការត្រូវបង្កើតឡើងដោយអគ្គនាយក បន្ទាប់ពីប្រឹក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ ជាភាសាអាឡឺម៉ង់ ភាសាជប៉ុន ព័រទុយហ្គាល់ ភាសារុស្ស៊ី ភាសាអេស្ប៉ាញ និងភាសា ផ្សេងទៀតដែលកំណត់ដោយសន្និបាត។

(៣)

(ក) អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លង២(ពីរ)ច្បាប់នៃអត្ថបទចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ ដែលបញ្ជាក់ថាត្រឹមត្រូវដោយអគ្គនាយក ទៅរដ្ឋាភិបាលនៃប្រទេសទាំងឡាយដែលបានចុះហត្ថលេខា និង តាមការស្នើសុំ ទៅរដ្ឋាភិបាលប្រទេសផ្សេងៗទៀត។ អគ្គនាយកត្រូវបញ្ជូនផងដែរនូវច្បាប់ចម្លងមួយច្បាប់ ដែលបញ្ជាក់ថាត្រឹមត្រូវ ទៅអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។

(ខ) អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លង២(ពីរ)ច្បាប់នៃវិសោធនកម្មណាមួយនៃកិច្ចព្រមព្រៀងនេះ ដែលបញ្ជាក់ថាត្រឹមត្រូវដោយអគ្គនាយក ទៅរដ្ឋាភិបាលនៃប្រទេសទាំងឡាយនៃសហភាពពិសេស ហើយ តាមការស្នើសុំ ទៅរដ្ឋាភិបាលនៃប្រទេសផ្សេងៗទៀត។ អគ្គនាយកត្រូវបញ្ជូនផងដែរនូវច្បាប់ចម្លងមួយច្បាប់ ដែលបញ្ជាក់ថាត្រឹមត្រូវ ទៅអគ្គលេខាធិការនៃក្រុមប្រឹក្សាអឺរ៉ុប។

(គ) តាមការស្នើសុំ អគ្គនាយកត្រូវផ្តល់ឱ្យរដ្ឋាភិបាលនៃប្រទេសណាមួយដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ឬចូលជាសមាជិកកិច្ចព្រមព្រៀងនេះ នូវច្បាប់ចម្លងនៃចំណាត់ថ្នាក់ ដែលបានបញ្ជាក់ថាត្រឹមត្រូវដោយអគ្គនាយក ជាភាសាអង់គ្លេស ឬភាសាបារាំង។

(៤) អគ្គនាយកត្រូវចុះបញ្ជីកិច្ចព្រមព្រៀងនេះ នៅឯលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

(៥) អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់ដែលជាភាគីអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និង អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអឺរ៉ុបពីៈ

(i) ការចុះហត្ថលេខា

(ii) ការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក

(iii) កាលបរិច្ឆេទការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

(iv) ខដាក់លក្ខខណ្ឌស្តីពីការប្រើប្រាស់ចំណាត់ថ្នាក់

(v) ការទទួលយកវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ

(vi) កាលបរិច្ឆេទដែលវិសោធនកម្មទាំងនេះចូលជាធរមាន

(vii) និងការទទួលបានការប្រកាសដកខ្លួនចេញ។

## មាត្រា១៧

## អន្តរបទប្បញ្ញត្តិ

(១) អំឡុងពេល២(ពីរ)ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប្រទេសទាំងឡាយជាភាគីអនុសញ្ញាអឺរ៉ុប ដែលមិនទាន់ជាសមាជិកនៃសហភាពពិសេសនេះ អាចទទួលបានសិទ្ធិដូចគ្នាក្នុងគណៈកម្មាធិការជំនាញ ដូចនឹងប្រទេសជាសមាជិកនៃសហភាពពិសេស ប្រសិនបើប្រទេសទាំងនេះចង់បាន។

(២) អំឡុងពេល២(ពីរ)ឆ្នាំបន្ទាប់ពីផុតអាជ្ញាយុកាលនៃរយៈពេលដូចចែងក្នុងកថាខណ្ឌទី(១) ប្រទេសទាំងឡាយដូចមានចែងក្នុងកថាខណ្ឌនេះអាចតំណាងដោយអ្នកសង្កេតការណ៍ក្នុងរាល់កិច្ចប្រជុំគណៈកម្មាធិការជំនាញ ហើយប្រសិនបើគណៈកម្មាធិការនេះសម្រេចដូច្នេះ អាចតំណាងដោយអ្នកសង្កេតការណ៍ក្នុងអនុគណៈកម្មាធិការឬក្រុមការងារដែលបង្កើតដោយគណៈកម្មាធិការនេះ។ ក្នុងអំឡុងពេលដូចគ្នា ប្រទេសទាំងឡាយអាចបញ្ជូនសំណើសុំវិសោធនកម្មចំណាត់ថ្នាក់ ដូចមានចែងក្នុងមាត្រា៥(៥) និងត្រូវបានជូនដំណឹងពីសេចក្ដីសម្រេចនិងអនុសាសន៍នៃគណៈកម្មាធិការជំនាញដូចមានចែងក្នុងមាត្រា៦(១)។

(៣) អំឡុងពេល៥(ប្រាំ)ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប្រទេសទាំងឡាយជាភាគីអនុសញ្ញាអឺរ៉ុប ដែលមិនទាន់ជាភាគីនៃសហភាពពិសេស អាចតំណាងដោយអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំទាំងអស់នៃសន្និបាត
ហើយប្រសិនបើសន្និបាតសម្រេចដូច្នេះ
អាចតំណាងដោយអ្នកសង្កេតការណ៍ក្នុងគណៈកម្មាធិការណាមួយ ឬក្រុមការងារដែលបង្កើតដោយសន្និបាត។